ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

FUTABA MICROFINANCE PLC.

# របាយការណ៍ប្រចាំឆ្នាំ

# ២០១៦

សុបិនក្លាយជាការពិត

# ប្រតិបត្តិការសំខាន់ៗ

| បរិយាយ | ៣១ ធ្នូ ២០១៦ |
| --- | --- |
| ចំនួនការិយាល័យសាខា | ៤ |
| ចំនួនបុគ្គលិកសរុប | ៩០ |
| ចំនួនមន្ត្រីឥណទានសរុប | ២០ |
| ចំនួនរាជធានី-ខេត្តប្រតិបត្តិការ | ៧ |
| ចំនួនស្រុកប្រតិបត្តិការ | ២៥ |
| ចំនួនភូមិប្រតិបត្តិការ | ១៦០ |
| ចំនួនអតិថិជនឥណទានសរុប | ៣៣២ |
| សម្ពាធឥណទានសរុប (គិតជាដុល្លារ) | ៦.៣៤៧.២៤១ |
| សម្ពាធឥណទានមានហានិភ័យសរុប (PAR %) | ០,០០ % |
| សម្ពាធឥណទានសម្រាប់មន្ត្រីឥណទានម្នាក់ (គិតជាដុល្លារ) | ៣១៧.៣៦២ |
| សម្ពាធឥណទានសម្រាប់បុគ្គលិកម្នាក់ (គិតជាដុល្លារ) | ៧០.៥២៤ |
| សម្ពាធឥណទានគិតជាមធ្យម (គិតជាដុល្លារ) | ២០.៥៤១ |
| ទ្រព្យសកម្មសរុប (គិតជាដុល្លារ) | **៧.៥៥៨.៨២៣** |

# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

## របាយការណ៍សមតុល្យ

៣១ ធ្នូ ២០១៦
(ធ្វើសវនកម្មរួច)
(គិតជា ដុល្លារ)

### ទ្រព្យសកម្ម

| | |
|---|---|
| សាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅធនាគារ | ៥៧៦.៥៧៩ |
| សម្ពាធឥណទានបានផ្តល់ជូនអតិថិជនសរុប | ៦.៣៤៧.២៤១ |
| ទ្រព្យសម្បត្តិ និងឧបករណ៍-សម្ភារៈសរុប | ៤៧៨.៦៥៦ |
| ទ្រព្យសម្បត្តិផ្សេងៗ | ១៥៦.៣៤៧ |
| **សរុបទ្រព្យសកម្ម** | **៧.៥៥៨.៨២៣** |

### បំណុល

| | |
|---|---|
| បំណុលផ្សេងៗ និងសំវិធានធន | ៤៤៨.៨៥៩ |
| កម្ចីរយៈពេលវែង និងកម្ចីរយៈពេលខ្លី | ៧០៨.៣២១ |
| **បំណុលសរុប** | **១.១៥៧.១៨០** |

### មូលធនភាគទុនិក

| | |
|---|---|
| មូលធនភាគទុនិកសរុប | ៦.៤០១.៦៤៣ |
| សរុបបំណុល និងមូលធនភាគទុនិក | **៧.៥៥៨.៨២៣** |

## របាយការណ៍ចំណូល និងចំណាយ

៣១ ធ្នូ ២០១៦
(ធ្វើសវនកម្មរួច)
(គិតជា ដុល្លារ)

| | |
|---|---|
| ចំណូលការប្រាក់ និងថ្លៃសេវាផ្សេងៗ | ៣៦៧.៤៣០ |
| ចំណាយប្រតិបត្តិការសរុប | ៨៨៤.៣១២ |
| ប្រាក់ចំណេញសុទ្ធបន្ទាប់ពីបង់ពន្ធ | **(៥១៦.៨៨២)** |

# មាតិកា

របាយការណ៍ប្រចាំឆ្នាំ | ២០១៦


០១ **បរិយាកាសទូទៅ នៃវិស័យធនាគារ និងហិរញ្ញវត្ថុ នៅកម្ពុជា**

០២ **ព័ត៌មានទូទៅ របស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី**

*ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល* ០៤

*ស្លាកសញ្ញារបស់គ្រឹះស្ថាន* **ហ្វូតាបា** *មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី* ០៥

*ប្រវត្តិសង្ខេបរបស់គ្រឹះស្ថាន* **ហ្វូតាបា** *មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី* ០៧

*សាររបស់ប្រធានក្រុមប្រឹក្សាភិបាល* ០៩

*សាររបស់នាយកប្រតិបត្តិ* ១១

## ០៣ ព័ត៌មានអាជីវកម្ម


| | |
|---|---|
| ភាគទុនិក និងដើមទុន | ១៤ |
| របនាសម្ព័ន្ធ | ១៥ |
| ក្រុមប្រឹក្សាភិបាល | ១៧ |
| គណៈគ្រប់គ្រង | ១៩ |
| ធនធានមនុស្ស | ២៣ |
| ផលិតផល និងសេវាកម្ម | ២៧ |
| អតិថិជន | ២៩ |
| របាយការណ៍សវនកម្មឯករាជ្យ | ៣១ |
| ទីតាំងបណ្តាញប្រតិបត្តិការ | ៤១ |


## ០៤ ដៃគូសហប្រតិបត្តិការ

# ០១

# បរិយាកាសទូទៅ នៃវិស័យធនាគារ និងហិរញ្ញវត្ថុ នៅកម្ពុជា




ទិដ្ឋភាពរួមនៃកំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០១៦ បានរងការរំខានខ្លះៗដោយឥទ្ធិពលនៃកត្តាមួយចំនួនរបស់បណ្តាប្រទេសអភិវឌ្ឍន៍នានាដែលក្នុងនោះរួមមាន៖ ការចាកចេញរបស់ប្រទេសអង់គ្លេសពីសហភាពអឺរ៉ុប (Brexit) កំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិកយឺតជាងការរំពឹងទុក ការបន្តថយចុះសន្សឹមៗនៃកំណើនសេដ្ឋកិច្ចចិនៗលៗ យ៉ាងណាមិញប្រទេសអាស៊ាន-៥ នៅតែរក្សាបាននូវសន្ទុះកំណើនដ៏រឹងមាំដោយបានពឹងផ្អែកជាចម្បងលើការអនុវត្តន៍គោលនយោបាយផ្តោតទៅរកតម្រូវការក្នុងស្រុក និងព្យាយាមទប់ស្កាត់កាត់បន្ថយផលប៉ះពាល់ពីខាងក្រៅ។ ទោះជាយ៉ាងណាប្រទេសកម្ពុជាក៏បានសម្រេចដោយជោគជ័យផងដែរនូវកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ ៧% និងបន្តស្ថិតលើគន្លងនៃកំណើនរយៈពេលវែង។

ការវិវឌ្ឍន៍ថ្មីៗ នៃវិស័យធនាគារហិរញ្ញវត្ថុនៅកម្ពុជានាឆ្នាំ ២០១៦នេះ បានបង្ហាញអំពីនិន្នាការបន្តរីកចម្រើន និងរឹងមាំគាំទ្រដោយបរិយាកាសអំណោយផលល្អជាទូទៅនៃស្ថិរភាព សន្តិសុខ និងការកើនឡើងនៃតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចស្ទើគ្រប់វិស័យ ដែលមានលក្ខណៈប្រទាក់ក្រឡាបំពេញគ្នាទៅវិញទៅមក។ ហើយកត្តាទាំងនេះត្រូវបានជំរុញ និងត្រួសត្រាយផ្លូវប្រកបដោយតម្វាភាពពីធនាគារជាតិនៃកម្ពុជា ស្របតាមទិសដៅអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។

អន្តរាគមន៍ប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ របស់ធនាគារជាតិនៃកម្ពុជាក្នុងការត្រួតពិនិត្យ តាមដានម៉ត់ចត់ និងវាយតម្លៃប្រតិបត្តិការហិរញ្ញវត្ថុជាប់ជាប្រចាំ ជាពិសេសការវិវឌ្ឍន៍នៃធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធទាំងឡាយ ក៏ដូចជាបានដាក់ចេញនូវបទបញ្ញត្តិនានា ការផ្សព្វផ្សាយគោលនយោបាយហិរញ្ញវត្ថុថ្មីៗទាន់ពេលវេលា បានជួយជំរុញបន្ថែមទៀតក្នុងដំណើរការធ្វើឲ្យមានស្ថិរភាពក្នុងវិស័យធនាគារហិរញ្ញវត្ថុបច្ចុប្បន្ន និងតទៅមុខយូរអង្វែង។ កត្តានេះបានរួមចំណែកយ៉ាងធំធេងទាក់ទាញទំនុកចិត្តពីប្រជាពលរដ្ឋកម្ពុជាកាន់តែច្រើន បន្តគាំទ្រប្រើប្រាស់សេវាកម្មធនាគារហិរញ្ញវត្ថុ ឲ្យដំណើរការរីកចម្រើនរឹងមាំ។

គួរកត់សម្គាល់ផងដែរថា ដោយមានតម្រូវការកើនឡើងនូវការប្រើប្រាស់របស់ប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាការហូរចូលនៃក្រុមហ៊ុនវិនិយោគបរទេសលើវិស័យសំខាន់ៗជាបន្តបន្ទាប់ បានធ្វើឲ្យមានការទាក់ទាញការវិនិយោគបន្ថែមក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលមកទល់ពេលបច្ចុប្បន្ននេះស្ថាប័នឯកជនដែលចូលរួមធ្វើប្រតិបត្តិការ ផ្តល់សេវាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជារួមមាន៖ ធនាគារពាណិជ្ជ៣៦ ធនាគារឯកទេស១៤ ការិយាល័យតំណាងធនាគារឯកទេស៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៥៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន៧ ប្រតិបត្តិករភតិសន្យាហិរញ្ញវត្ថុ១១ ក្រុមហ៊ុនក្រេឌីតបញ្ញើ... 

តាមការរំពឹងទុក វិស័យធនាគារ និងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា នឹងបន្តរីកចម្រើនទៅមុខថែមទៀត ដោយផ្អែកទៅលើភាពចាំបាច់ នៃតម្រូវការប្រើប្រាស់ហិរញ្ញវត្ថុក្នុងប្រទេស គាំទ្រការអភិវឌ្ឍន៍អាជីវកម្មស្ទើរគ្រប់វិស័យដូចជា៖ វិស័យវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ វិស័យទេសចរណ៍ វិស័យសំណង់ វិស័យពាណិជ្ជកម្មៗល។ ទន្ទឹមនឹងនេះដែរ ការធ្វើសមាហរណកម្មក្នុងតំបន់អាស៊ាន អាស៊ានបូកបី និងអន្តរជាតិនានា ក៏នឹងចូលរួមបង្កើនភាពរឹងមាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុកម្ពុជា តាមរយៈការទទួលបាននូវប្រែកពទុនសម្បូរបែប និងមានស្ថិរភាព ពីទីផ្សារអន្តរជាតិ ក៏ដូចជាបច្ចេកវិទ្យាទំនើប សម្រួលដល់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ក្រោមការគ្រប់គ្រងម៉ត់ចត់ពីធនាគារជាតិនៃកម្ពុជា ដែលជាស្ថាប័នអាណាព្យាបាល។

(ប្រភព: របាយការណ៍ធនាគារជាតិនៃកម្ពុជា "វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារឆ្នាំ២០១៦ និងទស្សនវិស័យឆ្នាំ២០១៧"។



០២

# ព័ត៌មានទូទៅរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី



# ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល

## ទស្សនៈវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយឲ្យល្អប្រសើរនូវកម្រិតជីវភាពរស់នៅរបស់អតិថិជននាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី។

## បេសកកម្ម

ផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលទុកចិត្តបំផុតទៅកាន់សហគ្រាសខ្នាតមធ្យម ខ្នាតតូច ខ្នាតតូចបំផុត និងរូបវន្តបុគ្គល ដោយបង្កើតនូវទីផ្សារដែលមានស្ថិរភាព ដើម្បីគាំទ្រទាំងអតិថិជននាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ព្រមទាំងចូលរួមក្នុងសកម្មភាពសង្គម ដើម្បីសម្រេចនូវគោលបំណង ឬ ក្តីសុបិនរបស់ពួកគាត់ ជាមួយអនាគតដ៏ប្រសើរ។

## តម្លៃស្នូល



# ស្លាកសញ្ញារបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

FUTABA MICROFINANCE PLC.

## និមិត្តសញ្ញា និងអត្ថន័យ

និមិត្តសញ្ញាសម្គាល់ នេះ គឺសំដៅលើត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចមួយ ដែលបែកពន្លកចេញពីស្រទាប់ដី។

ត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចនេះ អាចលូតលាស់ជាឈើដ៏ធំមួយដើមនាពេលអនាគតដ៏ឆាប់រហ័ស គឺអាស្រ័យលើការខិតខំបីបាច់ថែទាំ និងដាក់ជីយ៉ាងល្អិតល្អន់របស់យើងទាំងអស់គ្នា។

ក្នុងន័យនេះ យើងខ្ញុំជាគ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ប្រៀបបានទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុដ៏តូចមួយ ដែលទើបតែចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន លើវិស័យហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ហើយយើងខ្ញុំអាចអភិវឌ្ឍជាធនាគារឈានមុខមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគតខាងមុខ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាពខ្ពស់ ធានាឲ្យបាននូវស្ថិរភាព និងផ្តល់អនាគតដ៏ត្រចះត្រចង់ បម្រើជូនសាធារណៈជនទាំងអស់របស់គ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ឬក៏ធនាគារ **ហ្វូតាចា** ប្រៀបដូចជាត្រួយនៃពន្លកធញ្ញជាតិដ៏តូចរីកលូតលាស់ទៅជាដើមឈើដ៏ធំនាពេលអនាគតដ៏ខ្លីខាងមុខ។

គ្រឹះស្ថានយើងខ្ញុំអាចអភិវឌ្ឍឆាប់រហ័សប្រៀបដូចនឹងដើមឈើដ៏ធំ គឺអាស្រ័យលើបុគ្គលិកគ្រប់លំដាប់ថ្នាក់នីមួយៗនៃគ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ផងដែរ ហើយក៏ពឹងផ្អែកលើទំហំទុនដែលគ្រឹះស្ថានទទួលបានពីភាគទុនិករបស់ខ្លួន ដើម្បីបម្រើសេចក្តីត្រូវការរបស់អតិថិជនយើងខ្ញុំ។

| ពណ៌ | ពាក្យស្លោក |
|---|---|
| ពណ៌បៃតងនៃត្រួយពន្លកគ្រាប់ធញ្ញជាតិ គឺសំដៅភាពយកចិត្តទុកដាក់លើបរិស្ថាន ភាពសុខុដុម រវាងកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាននាពេលបច្ចុប្បន្ន និងតទៅអនាគតសម្រាប់ជំនាន់ក្រោយ។ | **សុបិនក្លាយជាការពិត** |

# ប្រវត្តិសង្ខេបរបស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី



## ១ សាខាការិយាល័យកណ្ដាល

*អាជ្ញាប័ណ្ណលេខៈ ម.ហ-៦៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានបង្កើតឡើងស្របតាមគោលបំណង និងក្ដីសុបិនរបស់ភាគទុនិក តាមរយៈគំនិតផ្ដួចផ្ដើម ព្រមទាំងការប្ដេជ្ញាចិត្តខ្ពស់ ភាគទុនិកបានជំនះនូវរាល់ឧបសគ្គទាំងឡាយ រហូតទទួលបានអាជ្ញាប័ណ្ណផ្លូវការពីធនាគារជាតិនៃកម្ពុជា លេខៈ ម.ហ-៦៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

ដើមឆ្នាំ២០១៦ គ្រឹះស្ថានក៏បានចាប់ផ្ដើមប្រតិបត្តិការអាជីវកម្មជាមួយដើមទុនដំបូងចំនួន **$ ១.000.000** ដោយទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនជាច្រើន ដែលបង្ហាញពីភាពជោគជ័យដ៏ត្រចះត្រចង់។

ជាមួយគ្នានេះផងដែរក្នុងឆ្នាំ ២០១៦នេះ ក្រុមហ៊ុន **AZUMA & Co., Ltd.** ក៏បានក្លាយជាភាគទុនិកថ្មីរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ក្រុមហ៊ុន **AZUMA & Co., Ltd.** ជាក្រុមហ៊ុនជប៉ុនដែលមានគោលគំនិតស្របគ្នា ក្នុងការគាំទ្រលើកស្ទួយកម្រិតជីវភាព ស្តង់ដាររស់នៅជូនដល់ពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្ដល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នឹងបន្តអនុវត្តផែនការគោលរបស់ខ្លួន ដើម្បីសម្រេចឲ្យបាននូវវត្ថុបំណងនៃក្ដីសុបិន របស់ភាគទុនិក។ ជាក់ស្តែងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ីបានបង្កើតការិយាល័យសាខាថ្មីចំនួនបី (៣)បន្ថែមទៀត នៅចុងឆ្នាំ ២០១៦នេះ ដើម្បីពង្រីកនូវសក្ដានុពលរបស់ខ្លួនគ្របដណ្ដប់លើវិសាលភាពទីផ្សារទូលំទូលាយ និងឆ្លើយតបទៅតាមកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់។ សាខាបើកថ្មីទាំងបី (៣)នោះ ត្រូវបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាដែលរួមមានដូចខាងក្រោម៖



## ២ សាខាខណ្ឌទួលគោក

*អាជ្ញាប័ណ្ណលេខៈ ម.ហ ៦៤-១២/០៤/០៨/០១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦*





**៣ សាខាខណ្ឌពោធិ៍សែនជ័យ**
អាជ្ញាប័ណ្ណលេខ: ម.ហ ៦៤-១២/០៩/០៤/០១
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦

**៤ សាខាក្រុងច្បារមន**
អាជ្ញាប័ណ្ណលេខ: ម.ហ ៦៤-០៥/០២/០១/០១
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦

ទន្ទឹមគ្នានេះដែរ គ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក៏បានធ្វើការបង្កើនដើមទុនជាបន្តបន្ទាប់ ប្រកបដោយជោគជ័យ ដែលត្រូវបានធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

ដើមទុនដំបូងចំនួន
**១.០០០.០០០** ដុល្លារ
ថ្ងៃ១៦ ខែធ្នូ ឆ្នាំ២០១៥

ថ្ងៃ១៦ ខែមិថុនា ឆ្នាំ២០១៦
បន្ថែមដើមទុនចំនួន
**១.០០០.០០០** ដុល្លារ

បន្ថែមដើមទុនចំនួន
**៥.០០០.០០០** ដុល្លារ
ថ្ងៃ២៣ ខែធ្នូ ឆ្នាំ២០១៦



# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល



លោក ច្រឹក ផល្លី ប្រធានក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចក្នុងអត្រាជិត ៧% ក្នុងឆ្នាំ២០១៦ ហើយក៏រំពឹងថានឹងបន្តកំណើនរបស់ខ្លួន ប្រកបដោយនិរន្តរភាពនាឆ្នាំបន្តបន្ទាប់ទៀត។

ការរក្សាបាននូវកំណើនជាបន្តបន្ទាប់នេះ ហើយវិស័យហិរញ្ញវត្ថុមានមូលដ្ឋាន រឹងមាំគួរឲ្យកត់សម្គាល់ យើងខ្ញុំក៏បានបោះជំហានដំណើរការអាជីវកម្មជាគ្រឹះស្ថានហិរញ្ញវត្ថុមួយក្នុងព្រះរាជាណាចក្រកម្ពុជានាដើមឆ្នាំ២០១៦។

ស្ថានភាពអំណោយផលខាងលើធ្វើឲ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រេចបាននូវសមិទ្ធផលធំៗគួរជាទីកត់សម្គាល់ ដែលទាំងអស់នេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន ដែលជានិច្ចកាលតែងតែគាំទ្រ **ហ្វូតាបា** គួរជាទីមោទនៈ។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីសោមនស្សរីករាយឥតឧបមា ចំពោះសមិទ្ធផលដ៏ថ្លៃថ្លា ដែលយើងខ្ញុំសម្រេចបាននាឆ្នាំដំបូងនេះ ប្រកបដោយអនុលោមភាពនៃគោលការណ៍ច្បាប់ និងបទដ្ឋានគតិយុត្តិរបស់ព្រះរាជាណាចក្រកម្ពុជា ហើយក៏សូមជម្រាបជូនអំពីសមិទ្ធផល ដែលសម្រេចបានខាងក្រោមនេះ៖



* ទ្រព្យសកម្មសរុបចំនួន ៧.៥៥៨.៨២៣ ដុល្លារ
* សំពាធឥណទានសរុបចំនួន ៦.៣៤៧.២៤១ ដុល្លារ
* អនុបាតឥណទានមិនដំណើរការស្មើនឹង ០,០០%
* អនុបាតសោធនភាពត្រូវបានរក្សាក្នុងកម្រិត ៨៧,៣៥%
* អតិថិជនខ្ចីឥណទានមានសរុបចំនួន ៣៣២នាក់
* សាខាចំនួនបួន (៤) ត្រូវបានបើកធ្វើប្រតិបត្តិការរបស់ខ្លួនជាបន្តបន្ទាប់តាមផែនការដែលបានគ្រោងទុក

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នឹងបន្តខិតខំសម្រិតសម្រាំងផ្តល់នូវផលិតផល និងសេវាកម្មប្រសើរបំផុតជូនអតិថិជនទាំងអស់ក្នុងពេលខាងមុខនេះ ពោលគឺអតិថិជន និង **ហ្វូតាបា** មានក្តីសុបិនរួមគ្នាតែមួយ។

ភាគទុនិកជប៉ុនរបស់យើងខ្ញុំ មានសុឆន្ទៈចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សជំនាន់ក្រោយនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏មានការតាំងចិត្តខ្ពស់ថា នឹងបន្ថែមដើមទុនច្រើនជាងមុនមកឲ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងឆ្នាំខាងមុខៗនេះ។

បុគ្គលិកគ្រប់លំដាប់ថ្នាក់ទាំងអស់នៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមធ្វើគារវកិច្ចចំពោះអតិថិជនទាំងអស់របស់ខ្លួន បំពេញសមត្ថកិច្ចលើបេសកកម្មរបស់ខ្លួនឲ្យទៅជាសកម្មភាពដ៏ពិតប្រាកដ ប្រកបដោយតម្លាភាព និងទំនួលខុសត្រូវខ្ពស់ ដើម្បីនាំមកនូវសមិទ្ធផលដ៏ធំធេងជូនដល់អតិថិជន ក៏ដូចជាសង្គមជាតិនៃកម្ពុជា ទាំងមូលផងដែរ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសារជាថ្មីម្តងទៀត ជូនចំពោះអតិថិជន ក៏ដូចជាជូនចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់ ជាពិសេសចំពោះធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ ដើម្បីចាត់ចែងនូវរាល់សកម្មភាពការងារទាំងអស់ប្រកបដោយតម្លាភាព រហូតមកដល់ពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។

យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ ចូរកើតមានដល់លោកអ្នក និងក្រុមគ្រួសារ សេចក្តីចម្រើនមានបាន ជោគជ័យគ្រប់ភារកិច្ចការងារ ជានិច្ចនិរន្តតរៀងទៅ។

**លោក ច្រឹក ផល្លី**
ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់នាយកប្រតិបត្តិ



លោក Junichi SASAKI នាយកប្រតិបត្តិ

ជូនចំពោះអតិថិជន និងដៃគូពាណិជ្ជកម្មជាទីគោរព !

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទទួលបានអាជ្ញាប័ណ្ណជាស្ថាប័នហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា ហើយក៏បានចាប់ផ្តើមធ្វើសកម្មភាពអាជីវកម្ម នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និងកំពុងបន្តពង្រីកប្រតិបត្តិការរបស់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ។

យើងសង្ឃឹម និងជឿជាក់ថា គ្រឹះស្ថានយើងខ្ញុំនឹងក្លាយជាមាគ៌ា សម្រាប់អ្នកជំនាន់ក្រោយកម្ពុជា ដែលសម្រេចយកភាពត្រឹមត្រូវ ស្មើគ្នា និងរក្សាឲ្យបាននូវតម្លាភាពជាមូលដ្ឋានក្នុងវិស័យសេវាហិរញ្ញវត្ថុ។

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានការគាំទ្រមូលនិធិពីភាគទុនិកឯកកម្មសិទ្ធិនៃប្រទេសជប៉ុន ដែលយើងខ្ញុំអាចចាត់ចែងប្រកបដោយភាពស្ទាត់ជំនាញ និងផ្តល់សេចក្តីសម្រេចចិត្តបានយ៉ាងឆាប់រហ័ស ដើម្បីបំពេញតាមតម្រូវការអតិថិជន។

ចក្ខុវិស័យរបស់យើងខ្ញុំ គឺធ្វើខ្លួនឲ្យក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពក្នុងពេលបច្ចុប្បន្ន និងពេលអនាគតតាមរយៈការធ្វើឲ្យមានលំនឹង ស្ថិរភាព និងតម្លាភាពលើផ្នែកទីផ្សារ



ហិរញ្ញវត្ថុនៅកម្ពុជា ដែលជាបំណងប្រាថ្នាដ៏សុចរិត ក៏ដូចជាគោលដៅរបស់គ្រឹះស្ថានយើងខ្ញុំផងដែរ។

ក្ដីសុបិនយើងខ្ញុំ គឺផ្ដល់ការគាំទ្រច្រើនបែបជូនដល់អតិថិជន ក៏ដូចជាសង្គម ដែលបង្កើតជាមូលដ្ឋានហិរញ្ញវត្ថុដើម្បីសាងអនាគតដ៏ត្រចះត្រចង់របស់ពួកគាត់។

លើសពីនេះ ខ្ញុំសូមគូសបញ្ជាក់ឡើងវិញថា ការរក្សាឲ្យបាននូវសេវាល្អបំផុត និងភាពទទួលខុសត្រូវដ៏ល្អឥតខ្ចោះនេះ ធ្វើឲ្យគ្រឹះស្ថានយើងខ្ញុំមានភាពខុសប្លែកពីសេវារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដទៃទៀត។

ជាមួយនឹងសកម្មភាពផ្ដល់ហិរញ្ញប្បទាន យើងខ្ញុំផ្ដោតលើទស្សនៈ "ជាដៃគូទុកចិត្តល្អឥតខ្ចោះរបស់អតិថិជន" តាមរយៈការផ្ដល់សេវាហិរញ្ញវត្ថុសម្បូរបែប រួមជាមួយនឹងសេវាកម្មប្រកបដោយជំនាញវិជ្ជាជីវៈ ដែលសមស្របទៅនឹងសំណើរ និងតម្រូវការរបស់អតិថិជនម្នាក់ៗដែលអញ្ជើញមកដាក់ពាក្យស្នើសុំក្នុងស្ថានភាពផ្សេងៗគ្នា និងទីតាំងខុសៗគ្នា។

អតិថិជនរបស់យើងខ្ញុំ នឹងទទួលបាននូវស្ថិរភាពហិរញ្ញវត្ថុលើការពង្រីកមុខរបរ និងអាជីវកម្មរបស់ខ្លួន តាមរយៈការផ្ដល់កញ្ចប់សេវាប្រសើរបំផុត ដែលមានការប្ដេជ្ញាចិត្តពីបុគ្គលិកជំនាញ និងប្រកបដោយវិជ្ជាជីវៈខ្ពស់ ដើម្បីផ្ដល់ជម្រើសហិរញ្ញវត្ថុសមស្របជាច្រើនបែបមកបំពេញតម្រូវការរបស់អតិថិជន។

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្ដល់នូវកញ្ចប់សេវាហិរញ្ញវត្ថុច្រើនបែបយ៉ាងមានដូចជា ឥណទានអាជីវកម្ម ឥណទានកសិកម្ម ឥណទានគេហដ្ឋាន ឥណទានសម្រាប់ប្រើប្រាស់ និងកម្ចីសម្រាប់ការសិក្សាក្នុងអត្រាការប្រាក់ទាបបំផុត ជាមួយគ្នានឹងសេវាល្អឥតខ្ចោះដែលមិនធ្លាប់មានជូនចំពោះអតិថិជន។

តទៅមុខ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី យើងខ្ញុំ ក៏សូមផ្ដល់ជូននូវសេវាដ៏សម្បូរបែប និងប្រកបដោយភាពច្នៃប្រឌិតខ្ពស់លើដំណោះស្រាយហិរញ្ញវត្ថុថ្មីៗ ជូនចំពោះអតិថិជនចាស់ ក៏ដូចជាអតិថិជនថ្មីទាំងអស់ តាមរយៈបច្ចេកវិទ្យាទំនើបៗ ដូចជាការប្រើប្រាស់កម្ចីតាមអនឡាញដោយស្នើសុំឥណទានតាមរយៈទូរស័ព្ទដៃទំនើបជាដើម។ល។

គ្រឹះស្ថានយើងខ្ញុំរង់ចាំសម្រេចក្ដីសុបិនរបស់លោកអ្នកគ្រប់ទីកន្លែងដែលយើងមានកិច្ចសហការរួមគ្នា ដើម្បីសម្រេចនូវគោលបំណងរួមរវាងលោកអ្នក និងគ្រឹះស្ថាន "ក្ដីសុបិនរបស់លោកអ្នកជាក្ដីសុបិនយើងខ្ញុំ" "អនាគតរបស់លោកអ្នកក៏ជាអនាគតរបស់យើងខ្ញុំផងដែរ"។

យើងខ្ញុំរីករាយស្វាគមន៍ផ្ដល់សេវាយ៉ាងកក់ក្ដៅ និងជាទីទុកចិត្តជូនអតិថិជនទាំងអស់ គ្រប់ពេលវេលាដែលលោកអ្នកត្រូវការ។

សូមសុបិនរបស់លោកអ្នកក្លាយជាការពិត។

**លោក Junichi SASAKI**
នាយកប្រតិបត្តិ



# ០៣

# ព័ត៌មានអាជីវកម្ម

# ភាគទុនិក និងដើមទុន



លោក **Yosuke SASAKI** ភាគទុនិក

**AZUMA & Co., Ltd.** ជាភាគទុនិកឯកកម្មសិទ្ធិ កាន់កាប់លើភាគហ៊ុន ១០០% របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមសម្តែងនូវសុឆន្ទៈ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា។

**AZUMA & Co., Ltd.** ជាសហគ្រាសជប៉ុនសុទ្ធសាធ ដែលរូបខ្ញុំ **Yosuke SASAKI** ជាជនជាតិជប៉ុន ទទួលកាន់កាប់លើភាគហ៊ុន ១០០% និងមានតួនាទីជាប្រធាននាយកនៃសហគ្រាស **AZUMA & Co., Ltd.**

យើងខ្ញុំមានកិត្តិយសក្រៃលែងក្នុងនាមជានីតិបុគ្គលនៃសហគ្រាស **AZUMA & Co., Ltd** ដែលបានចូលរួមចំណែកក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន និងថែរក្សាអ្នកជំនាន់ក្រោយ ក៏ដូចជាជួយលើកកម្ពស់កម្រិតស្តង់ដារការរស់នៅរបស់ពលរដ្ឋកម្ពុជាឲ្យកាន់តែប្រសើរឡើងៗនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគោលការណ៍តម្លាភាព ប្រសិទ្ធភាព និងការផ្តល់សេវាហិរញ្ញប្បទានប្រកបដោយនិរន្តរភាពយូរអង្វែងរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ីយើងខ្ញុំ។

**AZUMA & CO., LTD.**

**១00% នៃភាគហ៊ុន**

# រចនាសម្ព័ន្ធ


ភាគទុនិក
ក្រុមប្រឹក្សាភិបាល
នាយកប្រតិបត្តិ
នាយករង
នាយកប្រតិបត្តិ
ជំនួយការ
នាយកប្រតិបត្តិ
ជំនួយការ
នាយកប្រតិបត្តិ
នាយក នាយកដ្ឋាន
ឥណទាន
នាយករង នាយកដ្ឋាន
ឥណទាន
ប្រធានផ្នែក
វិភាគឥណទាន
ប្រធានផ្នែក
ត្រួតពិនិត្យឥណទាន
នាយក នាយកដ្ឋាន
ទីផ្សារ
នាយករង នាយកដ្ឋាន
ទីផ្សារ
មន្ត្រីជាន់ខ្ពស់ទីផ្សារ
នាយក នាយកដ្ឋាន
ប្រតិបត្តិការ
នាយករង នាយកដ្ឋាន
ប្រតិបត្តិការ
មន្ត្រីប្រតិបត្តិការ
នាយក នាយកដ្ឋាន
ហិរញ្ញវត្ថុ
នាយករង នាយកដ្ឋាន
ហិរញ្ញវត្ថុ
គណនេយ្យករ
មន្ត្រីពន្ធ
នាយក នាយកដ្ឋាន
ព័ត៌មានវិទ្យា
នាយករង នាយកដ្ឋាន
ព័ត៌មានវិទ្យា
មន្ត្រីព័ត៌មានវិទ្យា
នាយក នាយកដ្ឋាន
គាំទ្រ
ប្រធានផ្នែក
រដ្ឋបាល
ប្រធានផ្នែក
ធនធានមនុស្ស
សាខា
សាខា
សាខា
សាខា



# ក្រុមប្រឹក្សាភិបាល



### លោក ច្រឹក ផល្លី
### ប្រធានក្រុមប្រឹក្សាភិបាល

លោក ច្រឹក ផល្លី កើតនៅភ្នំពេញ ឆ្នាំ១៩៨១ សញ្ជាតិខ្មែរ។ លោកមានបទពិសោធន៍ជាង ១៤ឆ្នាំ ខាងផ្នែកគ្រប់គ្រង ដែលក្នុងរយៈពេល ៥ឆ្នាំ លោកបានបំពេញតួនាទីជាប្រធានគ្រប់គ្រងផ្នែកទីផ្សារ នៅក្រុមហ៊ុន **Futaba Co.,Ltd** ក្នុងឆ្នាំ២០០៧ លោកត្រូវបានតែងតាំងជានាយកចាត់ការទូទៅ ហើយបានបម្រើការងាររហូតមកដល់បច្ចុប្បន្ននេះ។ គាត់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យន័រតុន។ លោកត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ មកម្ល៉េះ។



### លោក Yosuke SASAKI
### អនុប្រធានក្រុមប្រឹក្សាភិបាល

ក្រុមហ៊ុន **AZUMA & CO., LTD** ជាក្រុមហ៊ុនជប៉ុន និងជាម្ចាស់ភាគហ៊ុន ១០០% ដែលតំណាងពេញច្បាប់ដោយ លោក **Yosuke SASAKI** មានតួនាទីជាប្រធាននាយក។

ក្រុមហ៊ុន **AZUMA & Co., Ltd.** ជាក្រុមហ៊ុនជប៉ុន មានគោលគំនិតស្របគ្នាក្នុងការគាំទ្រ លើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។



## បណ្ឌិត ចាប រតនា
### សមាជិកក្រុមប្រឹក្សាភិបាល

បណ្ឌិត ចាប រតនា បានចូលបម្រើការងារជាមួយ **ហ្វូតាចា** ក្នុងខែមករា ឆ្នាំ២០១៥ ជាទីប្រឹក្សាហិរញ្ញវត្ថុក្នុងស្រុកបន្ទាប់មកគាត់ក៏មកកាន់តំណែងជា នាយករងនាយកប្រតិបត្តិ នៅខែតុលា ឆ្នាំ២០១៥។ គាត់បានបញ្ចប់ថ្នាក់បណ្ឌិត គ្រប់គ្រងពាណិជ្ជកម្ម និងថ្នាក់អនុបណ្ឌិតគ្រប់គ្រងការអប់រំនៅសាកលវិទ្យាល័យបៀលប្រាយ។ អស់រយៈពេលជាង ២៥ឆ្នាំ គាត់ទទួលបានបទពិសោធន៍ការងារយ៉ាងច្រើនដូចជា អ្នកបកប្រែភាសា រដ្ឋបាល អ្នកគ្រប់គ្រងគំរោង និងជាអ្នកប្រឹក្សាយោបល់ក្នុងស្រុក ដែលមានទំនាក់ទំនងជាមួយនឹងមន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុងក្រសួងគ្រប់ខេត្ត-ក្រុង រួមជាមួយនិងដៃគូអភិវឌ្ឍ អង្គការសហប្រជាជាតិ, IO, អង្គការក្រៅរដ្ឋាភិបាល, វិស័យឯកជនក្នុងផ្នែកអភិវឌ្ឍផែនការថ្នាក់ជាតិ ហិរញ្ញវត្ថុ ស្ថិតិ ការអប់រំ M&E, Health based UNTAC, WHO-Ministry of Health, and UN-Ministry of Planning.



## ឯកឧត្តម អ៊ុក ចាយ
### ក្រុមប្រឹក្សាភិបាលឯករាជ្យ

ឯកឧត្តម អ៊ុក ចាយ ចាប់ផ្តើមការងារជាមួយគ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី ជាទីប្រឹក្សាច្បាប់ក្នុងស្រុកក្នុងខែកុម្ភៈ ឆ្នាំ២០១៥ ហើយលោកត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលឯករាជ្យក្នុងខែកក្កដា ឆ្នាំ២០១៥។ លោកបានទទួលបរិញ្ញាប័ត្រពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកមានបទពិសោធន៍ការងារជាង ៤៨ ឆ្នាំ ដែលរួមមានតួនាទីជាច្រើនដូចជា ទីប្រឹក្សាផ្នែកច្បាប់ អភិបាលស្រុក អភិបាលខេត្ត ស្តីទី អនុរដ្ឋលេខាធិការ និងលេខាធិការនៅក្នុងក្រសួងផែនការ។

# គណៈគ្រប់គ្រង



### លោក **Junichi SASAKI** នាយកប្រតិបត្តិ

លោក **Junichi SASAKI** បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យតូក្យូ នៅក្នុងឆ្នាំ ១៩៧៥ បច្ចុប្បន្ន ជាប្រធាន និងជាភាគទុនិក ១០០% នៃ **FutureBud International Co., Ltd** នៃប្រទេសជប៉ុន។



## បណ្ឌិត ចាប រតនា នាយករង នាយកប្រតិបត្តិ

បណ្ឌិត ចាប រតនា បានចូលបម្រើការងារជាមួយ **ហ្វតាចា** ក្នុងខែមករា ឆ្នាំ២០១៥ ជាទីប្រឹក្សាហិរញ្ញវត្ថុក្នុងស្រុក បន្ទាប់មកគាត់ក៏មកកាន់តំណែងជានាយករង នាយកប្រតិបត្តិ នៅខែ តុលា ឆ្នាំ២០១៥។ គាត់បានបញ្ចប់ថ្នាក់បណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម និងថ្នាក់អនុបណ្ឌិតគ្រប់គ្រងការអប់រំនៅសាកលវិទ្យាល័យបៀលប្រាយ។ អស់រយៈពេលជាង ២៥ឆ្នាំ គាត់ទទួលបានបទពិសោធន៍ការងារយ៉ាងច្រើនដូចជា អ្នកបកប្រែភាសា រដ្ឋបាល អ្នកគ្រប់គ្រងគំរោង និងជាអ្នកប្រឹក្សាយោបល់ក្នុងស្រុក ដែលមានទំនាក់ទំនងជាមួយ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុងក្រសួងគ្រប់ខេត្ត-ក្រុង រួមជាមួយនឹង ដៃគូអភិវឌ្ឍអង្គការសហប្រជាជាតិ, IO, អង្គការក្រៅ រដ្ឋាភិបាល, វិស័យឯកជនក្នុងផ្នែកអភិវឌ្ឍ ផែនការថ្នាក់ជាតិ, ហិរញ្ញវត្ថុ ស្ថិតិ ការអប់រំ M&E, Health based UNTAC, WHO-Ministry of Health, and UN-Ministry of Planning.



## លោក ព្រាប កណ្ដឹង ជំនួយការនាយកប្រតិបត្តិ

លោក ព្រាប កណ្ដឹង បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ (Master of Business Specializing in Finance) ពីសាកលវិទ្យាល័យ Charles Sturt University នៃប្រទេសអូស្ត្រាលី និងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគណនេយ្យ (BBA) នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លោកមានបទពិសោធន៍ធ្វើការជាច្រើនឆ្នាំដែលពាក់ព័ន្ធទៅនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ការសិក្សា ក៏ដូចជាបទពិសោធន៏ការងារបានធ្វើអោយគាត់មានការអភិវឌ្ឍន៏ជាបន្តបន្ទាប់នូវភាពរីកចំរើននៃអាជីពការងាររបស់គាត់។ មុនពេលគាត់ចូលរួមបំរើការងារជាមួយ **ហ្វតាចា** លោកព្រាប កណ្ដឹង មានបទពិសោធន៍ការងារជាច្រើនពាក់ពន្ធ័ទៅនឹងការគ្រប់គ្រងគណនេយ្យ ប្រឹក្សាយោបល់ផ្នែកគណនេយ្យ និងជានាយក នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ។ លោកបានចូលរួមជាមួយ **ហ្វតាចា** នៅឆ្នាំ ២០១៥ ដែលមានតួនាទីជានាយក នាយកដ្ឋានហិរញ្ញវត្ថុ។ នៅខែ កក្កដា ឆ្នាំ២០១៦ លោកត្រូវតែងតាំងតួនាទីជាជំនួយការនាយកប្រតិបត្តិ ដែលទទួលខុសត្រូវទៅលើនាយកដ្ឋានចំនួនបី ដូចជានាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានព័ត៌មានវិទ្យា និងនាយកដ្ឋានធនធានមនុស្ស&រដ្ឋបាល។



## លោក អ៊ុំ ពិសិដ្ឋ ជំនួយការនាយកប្រតិបត្តិ

លោក អ៊ុំ ពិសិដ្ឋ បានចាប់ផ្តើមអាជីពការងាររបស់លោកជាមួយ **ហ្វតាចា** នៅចុងឆ្នាំ២០១៥ ក្នុងតួនាទីជានាយក នាយកដ្ឋានឥណទាន បន្ទាប់មកនៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជាជំនួយការនាយកប្រតិបត្តិ ដែលត្រូវទទួលបន្ទុកគ្រប់គ្រង និងមើលការខុសត្រូវលើនាយកដ្ឋានចំនួនបី គឺនាយកដ្ឋានឥណទាន នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានទីផ្សារ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងទូទៅនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ទទួលបាននូវសញ្ញាប័ត្រភាសាអង់គ្លេសថ្នាក់ IEAP ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយបានចូលរួមវគ្គបណ្ដុះបណ្ដាល សន្និសិទ និងសិក្ខាសិលាជាច្រើន ដែលទាក់ទងទៅនឹងការវិវឌ្ឍន៍វិស័យអចលនទ្រព្យ ការគ្រប់គ្រងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ ចំពោះបទពិសោធន៍ការងារ លោកបានចំណាយពេលជាង ១១ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយនិងមុខតំណែងជាច្រើនដូចជា មន្ត្រីសាខា នាយកសាខា នាយកគ្រប់គ្រងតំបន់ នាយក នាយកដ្ឋានប្រតិបត្តិការ នាយក នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង នាយកគ្រប់គ្រងឥណទាន នាយក នាយកដ្ឋានឥណទាន។ លោកក៏បានចំណាយពេលជាងបីឆ្នាំ បម្រើការងារនៅវិស័យទូរគមនាគមន៍ផងដែរ។



## លោក ហួត សុខជា នាយក នាយកដ្ឋានប្រតិបត្តិការ

លោក ហួត សុខជា ចាប់ផ្ដើមការងារជាមួយ **ហ្វូតាចា** ក្នុងតួនាទីជានាយក នាយកដ្ឋានប្រតិបត្តិការនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលលោកបានគ្រប់គ្រងនូវរាល់កិច្ចការ និងសកម្មភាពទាំងអស់ នៅក្នុងការបង្កើតគោលនយោបាយ និងនីតិវិធីដែលទាក់ទងទៅនឹងផ្នែកបេឡា និងប្រតិបត្តិការសាខា។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកទីផ្សារ ហើយបានចូលរួមវគ្គបណ្ដុះបណ្ដាលសិក្ខាសាលា និងសន្និសីទជាច្រើនដែលទាក់ទងទៅនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ស្ថាប័នមីក្រូហិរញ្ញវត្ថុ។ លោកបានចំណាយពេលជាង ១៣ឆ្នាំ ជាមួយនិងបទពិសោធន៍ច្រើនផ្នែកដូចជាផ្នែកប្រតិបត្តិការ ផ្នែកលក់ ផ្នែកទីផ្សារ ស្រាវជ្រាវ និងការអភិវឌ្ឍផលិតផល ខណៈពេលដែលលោក បានចំណាយពេល ៨ឆ្នាំចុងក្រោយរបស់លោក នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុជាមួយស្ថាប័នដទៃទៀតមុនពេលដែលលោកបានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។



## លោក លឹម សំបូរ នាយក នាយកដ្ឋានទីផ្សារ

លោក លឹម សំបូរ កើតនៅខែមិថុនា ឆ្នាំ១៩៨១។ លោកបានចូលរួមជាមួយ **ហ្វូតាចា** នៅខែវិច្ឆិកា ឆ្នាំ ២០១៥ ក្នុងតួនាទីជានាយក នាយកដ្ឋានទីផ្សារ។ នៅមុនពេលចាប់ផ្ដើមអាជីពមួយនេះ លោកធ្លាប់បានបម្រើការងារ ជាមួយធនាគារធំៗចំនួនពីររួមមាន ធនាគារបរទេសថ្នាក់តំបន់ និងធនាគារក្នុងស្រុកមួយដែលមានបណ្ដាញប្រតិបត្តិការធំជាងគេផងដែរ។
ជាមួយបទពិសោធន៍រយៈពេលជាង១៤ឆ្នាំ ក្នុងវិស័យធនាគារហិរញ្ញវត្ថុ លោក សំបូរ ធ្លាប់បានទទួលខុសត្រូវនូវមុខងារជាច្រើនដូចជាប្រធានទំនាក់ទំនង ប្រធានផ្នែកឥណទានភតិសន្យា អនុប្រធានផ្នែកឥណទាន និងតួនាទីជាច្រើនទៀត ដែលលោកបានចំណាយពេលជាង ១០ឆ្នាំ ចូលរួមក្នុងសកម្មភាពជាច្រើននៃការលក់ដូរមុខៗ។ ដោយឡែក លោក សំបូរ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រពីសាកលវិទ្យាល័យបៀលប្រាយ ផ្នែកហិរញ្ញវត្ថុ និងធនាគារ (Finance and Banking) ក្នុងឆ្នាំ២០០៨។



## លោក គង់ សារ៉ាត់ នាយក នាយកដ្ឋានព័ត៌មានវិទ្យា

លោក គង់ សារ៉ាត់ កើតនៅឆ្នាំ ១៩៨៥។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម (MBA) នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០១១ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកព័ត៌មានវិទ្យា នៅសាកលវិទ្យាល័យបៀលប្រាយ ក្នុងឆ្នាំ២០០៨ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យន័រតុន នៅដើមឆ្នាំ ២០១៦។ ជាមួយនិងអតីតភាពការងារលោកមានតួនាទីជាប្រធានគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា នៃធនាគារពាណិជ្ជមួយនៅកម្ពុជា ដែលមានបទពិសោធជាង ៨ឆ្នាំក្នុងវិស័យធនាគារ ហើយលោកបានចូលបម្រើការងារនៅ **ហ្វូតាចា** ចាប់តាំងពីខែមករា ឆ្នាំ២០១៦ មកម្ល៉េះ។ បច្ចុប្បន្នលោកមានតួនាទីគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា។



## លោក ទុំ វ៉ាន់ហេង នាយក នាយកដ្ឋានឥណទាន

លោក វ៉ាន់ហេង កើតនៅឆ្នាំ ១៩៨៨ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យធនធានមនុស្សឆ្នាំ២០១១។ លោកបានចាប់ផ្ដើមអាជីពរបស់លោកជាមួយ **ហ្វូតាចា** ក្នុងតួនាទីជានាយករង នាយកដ្ឋានប្រតិបត្តិការនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ បន្ទាប់មក លោកត្រូវបានផ្លាស់ប្ដូរតួនាទីជានាយករង នាយកដ្ឋានឥណទាន ក្នុងខែមីនា ឆ្នាំ២០១៦។ ខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជានាយក នាយកដ្ឋានឥណទាន។ លោកមានបទពិសោធន៍ជាង ៧ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ មុនពេលដែលលោកចូលរួម ជាមួយ **ហ្វូតាចា**។ លោក វ៉ាន់ហេង បានចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រងហានិភ័យឥណទាន ការវិភាគឥណទាន ការដឹកនាំ និងការគ្រប់គ្រងជាដើម ។



# ធនធានមនុស្ស

## ១. ចំនួនបុគ្គលិក

ឆ្លើយតបទៅនឹងកំណើននៃតម្រូវការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុជារៀងរាល់ថ្ងៃ ក៏ដូចជាចក្ខុវិស័យរយៈពេលវែងរបស់គ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ការរៀបចំធនធានមនុស្សឲ្យបានគ្រប់គ្រាន់ ដើម្បីបម្រើសេវាជូនអតិថិជនប្រកបដោយប្រសិទ្ធភាព គឺជាកត្តាចាំបាច់បំផុត។ ទន្ទឹមនឹងនេះ គ្រឹះស្ថានក៏បានយកចិត្តទុកដាក់ក្នុងការជ្រើសរើសបុគ្គលិកមានសមត្ថភាពខ្ពស់ មកចូលរួមអនុវត្តបេសកកម្មផងដែរ ជាក់ស្តែងគិតត្រឹមបំណាច់ឆ្នាំ២០១៦នេះ ទិន្នន័យស្ថិតិបុគ្គលិករបស់ **ហ្វូតាចា** មានចំនួនសរុប ៩០នាក់ (បុរស ៥៧នាក់ និងស្ត្រី ៣៣នាក់) មានលម្អិតដូចខាងក្រោម៖

**ការិយាល័យកណ្តាល ២០១៦**

ចំនួនបុគ្គលិកសរុប **៥៥ នាក់**

ចំនួនបុគ្គលិកបុរស
**៣៩ នាក់**



ចំនួនបុគ្គលិកស្ត្រី
**១៦ នាក់**

**សាខាខណ្ឌទួលគោក ២០១៦**

ចំនួនបុគ្គលិកសរុប **១៣ នាក់**

ចំនួនបុគ្គលិកបុរស
**៦ នាក់**



ចំនួនបុគ្គលិកស្ត្រី
**៧ នាក់**







## ២. ការអភិវឌ្ឍន៍ធនធានមនុស្ស

គ្រឹះស្ថាន **ហ្វូតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី បានលើកទឹកចិត្តតាមរយៈការដំឡើងមុខងារតួនាទី និងប្រាក់បៀវត្សដល់បុគ្គលិកដែលមានស្នាដៃលេចធ្លោតាមទំហំការងាររៀងៗខ្លួន ព្រមទាំងបានផ្តល់នូវការបណ្តុះបណ្តាលជាប្រចាំដល់បុគ្គលិកតាមផ្នែកនីមួយៗ រួមមានទាំងការបណ្តុះបណ្តាលខាងក្នុង និងការចាត់បញ្ជូនបុគ្គលិកពាក់ព័ន្ធឲ្យចូលរួមវគ្គបណ្តុះបណ្តាលខាងក្រៅផងដែរ។

# សកម្មភាពបណ្តុះបណ្តាលបុគ្គលិក

◆ សកម្មភាពបណ្តុះបណ្តាលបុគ្គលិកខាងក្នុង





◆ សកម្មភាពចូលរួមវគ្គសិក្ខាសាលារបស់សមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា





# ផលិតផល និងសេវាកម្ម

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតឡើង និងដាក់ឲ្យដំណើរការនូវផលិតផល និងសេវាកម្មជាច្រើនសម្រាប់ផ្តល់ជូនអតិថិជនទៅតាមតម្រូវការប្រើប្រាស់ និងលំហូរសាច់ប្រាក់ជាក់ស្តែងរបស់ពួកគាត់ ដែលអាចធ្វើការជ្រើសរើសនូវជម្រើសដ៏សមស្របណាមួយដូចខាងក្រោម៖

## ឥណទានអាជីវកម្ម

. អតិថិជនគោលដៅ : អតិថិជនទូទៅដែលមានតម្រូវការសាច់ប្រាក់សម្រាប់ចាប់ផ្តើម ឬ ពង្រីកអាជីវកម្ម ដើម្បីបង្កើនប្រាក់ចំណេញ។

. ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក

. ទំហំឥណទាន : ៥០០ - ២០០.០០០

. រយៈពេលអតិបរិមា : ១០ ឆ្នាំ



## ឥណទានគេហដ្ឋាន

. អតិថិជនគោលដៅ : អតិថិជនដែលមាន តម្រូវការទិញផ្ទះ ឬ សាងសង់ផ្ទះសម្រាប់ស្នាក់នៅ និងប្រកបរបរ អាជីវកម្ម។

. ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក

. ទំហំឥណទាន : ៥០០ - ២០០.០០០

. រយៈពេលអតិបរិមា : ១០ ឆ្នាំ



## ឥណទានកសិកម្ម

. អតិថិជនគោលដៅ : អតិថិជនដែលមានមុខរបរកសិកម្ម ហើយត្រូវការសាច់ប្រាក់បន្ថែម ដើម្បីវិនិយោគបម្រើការឲ្យផ្នែកកសិកម្មរបស់ខ្លួន។

. ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក

. ទំហំឥណទាន : ៥០០ - ២០០.០០០

. រយៈពេលអតិបរិមា : ១០ ឆ្នាំ



## ឥណទានសម្រាប់ប្រើប្រាស់

. អតិថិជនគោលដៅ : អតិថិជនទូទៅ ដែលមានតម្រូវការសាច់ប្រាក់ ដើម្បីទិញឧបករណ៍សម្ភារៈផ្សេងៗ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។
. ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក
. ទំហំឥណទាន : ៥០០ - ២០០.០០០
. រយៈពេលអតិបរិមា : ១០ ឆ្នាំ



## កម្ចីសិក្សា

. អតិថិជនគោលដៅ : សម្រាប់អាណាព្យាបាល ឬ សិស្សនិស្សិត ដែលខ្វះខាតផ្នែកហិរញ្ញវត្ថុ សម្រាប់បង់ថ្លៃសិក្សា។
. ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក
. ទំហំឥណទាន : ៣០០ - ១.០០០
. រយៈពេលអតិបរិមា : ១ ឆ្នាំ



## ឥណទានបុគ្គលិក

. ឥណទានប្រភេទនេះ សម្រាប់ផ្តល់ជូនបុគ្គលិករបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី តែប៉ុណ្ណោះ។



គួរបញ្ជាក់ផងដែរថាក្នុងឆ្នាំ២០១៦នេះ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានផ្តល់ឥណទានជូនអតិថិជនទៅតាមប្រភេទនីមួយៗ ដែលគិតជាភាគរយមានដូចខាងក្រោម៖




ផលិតផល និង គិតជាភាគរយ

| | |
|---|---|
| ១. ឥណទានអាជីវកម្ម | ៣៤,៣២% |
| ២. ឥណទានគេហដ្ឋាន | ៣៦,៣៨% |
| ៣. ឥណទានកសិកម្ម | ០,១៤% |
| ៤. ឥណទានសម្រាប់ប្រើប្រាស់ | ២៦,៤០% |
| ៥. កម្ចីសិក្សា | ០,០២% |
| ៦. ឥណទានបុគ្គលិក | ២,៧៤% |

# អតិថិជន



អ្នកស្រី ស៊ិន សាលីន អាយុ ៤៧ ឆ្នាំ ជាអតិថិជនរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានទីលំនៅភូមិកំពង់សំណាញ់ ១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រកបរបរលក់គ្រឿងប៉ាក់-ឌិន នៅផ្សារទួលទំពូង។ អ្នកស្រីបានប្រើប្រាស់សេវាឥណទាន ជាមួយ **ហ្វូតាបា** រយៈពេលជិតមួយឆ្នាំមកហើយ។ គាត់បានបញ្ជាក់ថា ដើមទុនទាំងនេះ ត្រូវបានយកមកប្រើប្រាស់ដើម្បីបង្កើនស្តុកទំនិញ និងពង្រីកមុខរបរ។ ដោយសារការខិតខំប្រឹងប្រែង ក្នុងមុខជំនួញ និងដោយបានទុនបន្ថែមពី **ហ្វូតាបា** បានធ្វើឲ្យមុខរបររបស់គាត់មានការរីកចម្រើន និងមានប្រាក់ចំណេញកើនឡើងផងដែរ (ការរៀបរាប់របស់គាត់)។





លោក លី សឿន និងអ្នកស្រី អួន សុនី ត្រូវជាប្ដី-ប្រពន្ធ មានទីលំនៅភូមិព្រៃស្វាយ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ពួកគាត់បានប្រើប្រាស់សេវាឥណទានគេហដ្ឋានជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី រយៈពេលជិតមួយឆ្នាំមកហើយ។ លោក លី សឿន បានបញ្ជាក់ថា "យើងខ្ញុំមានសេចក្ដីពេញចិត្តណាស់ដោយបានមករស់នៅក្នុងផ្ទះថ្មីនេះ និងសូមអរគុណចំពោះ **ហ្វូតាបា** ដែលបានរួមចំណែកជួយសម្រេចក្តីសុបិនរបស់ពួកខ្ញុំ"។ ទោះយ៉ាងណាយើងខ្ញុំត្រូវខិតខំបន្ថែមទៀតក្នុងការរកចំណូល ក៏ដូចជាសន្សំសំចៃក្នុងការចំណាយ ដើម្បីធ្វើឲ្យជីវភាពគ្រួសារមានភាពកាន់តែល្អប្រសើរថែមទៀត។



លោក ប៉ន រស់ មានទីលំនៅភូមិតាផៅកណ្ដាល សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រកបមុខរបរដាំឈើ។ គាត់បានរីករាយជាមួយសេវាឥណទានសម្រាប់ប្រើប្រាស់របស់ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ លោក ប៉ន រស់ បានបញ្ជាក់ថា “ខ្ញុំត្រេកអរយ៉ាងខ្លាំងដោយ បានទទួលប្រាក់កម្ចីពី **ហ្វូតាបា** ហើយខ្ញុំក៏បានទិញរថយន្តមួយគ្រឿងនេះផងដែរ សូមអរគុណចំពោះ **ហ្វូតាបា** ដែលបានផ្ដល់ប្រាក់កម្ចីដល់ខ្ញុំ”។

# របាយការណ៍សវនកម្មឯករាជ្យ

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដែលមាននិរន្តរភាពជូនសហគ្រាសធុនតូច និងមធ្យម និងគ្រួសារ ដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានដូចខាងក្រោម:

| | ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ការិយបរិច្ឆេទចាប់ពី ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ២) | ដុល្លារអាមេរិក (មិនរងសវនកម្ម) | ពាន់រៀល (កំណត់សំគាល់ ២) (មិនរងសវនកម្ម) |
| ប្រាក់ចំណេញមុនបង់ពន្ធ | (៥១៣.០៨៣) | (២.០៧១.៣១៦) | (៨១.475) | (៣២៩.៩៧៣) |
| ពន្ធលើប្រាក់ចំណេញ | (៣.៧៩៩) | (១៥.៣៣៧) | - | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | **(៥១៦.៨៨២)** | **(២.០៨៦.៦៥៣)** | **(៨១.៤៧៥)** | **(៣២៩.៩៧៣)** |

## ភាគលាភ

ក្រុមហ៊ុនពុំបានប្រកាស ឬបង់ភាគលាភ និងក្រុមប្រឹក្សាភិបាលមិនបានផ្តល់អនុសាសន៍ ក្នុងការបែងចែកភាគលាភ ដែលត្រូវបង់ក្នុងការិយបរិច្ឆេទនេះទេ។

## ដើមទុន

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនមានចំនួន ៧.០០០.០០០ ដុល្លារអាមេរិក (ដែលមានតម្លៃស្មើរនឹង ២៨.២៥៩.០០០ ពាន់រៀល) (២០១៥: ១.០០០.០០០ ដុល្លារអាមេរិក) កាន់កាប់ទាំងស្រុងដោយ AZUMA & Co., Ltd. ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថា មិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ឥណទានដែលជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឲ្យឥណទានអាក្រក់ដែលបានជំរះចេញពីបញ្ជី ឬចំនួនសំវិធានធនជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

### ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

### វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ក្រៅអំពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុនចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវសង ឬអាចនឹងត្រូវសងក្នុងរយៈពេល ១២ ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ។

### ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាល មានមតិថាលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

# របាយការណ៍សវនកម្មឯករាជ្យ (ត)

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយនាថ្ងៃចេញរបាយការណ៍នេះ ដែលតម្រូវឲ្យមានការលាតត្រដាង ឬ និយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សំគាល់ ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមានៈ

- លោក ច្រឹក ផល្លី — ប្រធានក្រុមប្រឹក្សាភិបាល
- លោក Yosuke Sasaki — សមាជិក
- បណ្ឌិត ចាប រតនា — សមាជិក
- លោក អ៊ុក ចាយ — សមាជិកតតីយជន

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាលណា កាន់កាប់ ឬទទួលខុសត្រូវលើភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះទេ។

ផលប្រយោជន៍ដោយប្រយោល របស់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងនិងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុន ឬលិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតទេ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធនឹងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាល នោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីផ្តល់បង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវៈ

**(ក)** អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

**(ខ)** អនុវត្តទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹង ការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ គឺត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**(គ)** ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

**(ឃ)** វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការ ក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

**(ង)** ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញនៅទំព័រទី១០ ដល់ទី៥២ ដែលជាមតិរបស់យើងខ្ញុំ បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល:

លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល

លោក Junichi Sasaki
អគ្គនាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី: 22 MAR 2017

# របាយការណ៍សវនកម្មឯករាជ្យ (ត)

## *របាយការណ៍របស់សវនករឯករាជ្យ*

*ជូនចំពោះភាគទុនិក ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី*

### មតិសវនកម្ម

*យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានតារាងតុល្យការនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងរបាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងកំណត់សំគាល់ដែលរួមមាន គោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី១០ ដល់ទី៥២។*

*ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារ គណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និង ការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។*

### មូលដ្ឋាននៃមតិសវនកម្ម

*យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីធនាគារ ដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំ ប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្ម របស់យើងខ្ញុំ។*

### បញ្ហាផ្សេងទៀត

*យើងខ្ញុំ សូមទាញចំណាប់អារម្មណ៍ថាយើងមិនបានធ្វើសវនកម្មលើតារាងតុល្យការរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងរបាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ (កាលបរិច្ឆេទបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលបានភ្ជាប់ជាមួយ ឬព័ត៌មានពន្យល់ផ្សេងៗដែលពាក់ព័ន្ធ។ ហេតុនេះ យើងខ្ញុំមិនបញ្ចេញមតិសវនកម្មលើរបាយការណ៍ទាំងនោះឡើយ។*

### ព័ត៌មានផ្សេងៗ

*អ្នកគ្រប់គ្រង ទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី១ ដល់ទី៥ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថារួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។*

*មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។*

*ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍*

ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ យើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំ ពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន (ប្រសិនបើពាក់ព័ន្ធ) នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្ម របាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈត្តនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុស ឆ្គងដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ

# របាយការណ៍សវនកម្មឯករាជ្យ (ត)

ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណង ដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បី បញ្ចេញមតិ លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលធនាគារ បានប្រើប្រាស់ និងភាព សមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែល បានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ របស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិន ប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់ អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាង ព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋាន របស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្ម របស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យធនាគារបញ្ឈប់ និរន្តរភាពអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំង ការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូល ទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុង ដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់




ខៃ ហ៊ុយ
*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 22 MAR 2017

# តារាងតុល្យការ

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សំគាល់ | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ពាន់រៀល (កំណត់សំគាល់៤) | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដុល្លារអាមេរិក (មិនរងសវនកម្ម) | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពាន់រៀល (កំណត់សំគាល់៤) (មិនរងសវនកម្ម) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ១២.៥៦៣ | ៥០.៧១៧ | ៥៨១.៥០៧ | ២.៣៥៥.១០៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៦ | ៣៥៩.៨៣២ | ១.៤៥២.៦៤២ | ៥៣.៧៩៤ | ២១៧.៨៦៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | ៧ | ២០៤. ១៨៤ | ៨២៤.២៩១ | ១.៧៩២ | ៧.២៥៨ |
| ឥណទានផ្តល់ដល់អតិថិជន | ៨ | ៦.៣៤៧.២៤១ | ២៥.៦២៣.៨១២ | - | - |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ១៥៦.៣៤៧ | ៦៣១.១៧៣ | ៩០.០០០ | ៣៦៤.៥០០ |
| ទ្រព្យ និងបរិក្ខារ | ១០ | ៤៦១.២៣៩ | ១.៨៦២.០២២ | ១៩៧.៩៣៣ | ៨០១.៦២៩ |
| ទ្រព្យសកម្មអរូបី | ១១ | ១៧.៤១៧ | ៧០.៣១២ | ៣៦៣ | ១.៤៧០ |
| **សរុបទ្រព្យសកម្ម** | | **៧.៥៥៨.៨២៣** | **៣០.៥១៤.៩៦៩** | **៩២៥.៣៨៩** | **៣.៧៤៧.៨២៦** |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១២ | ១៤៨.១២៨ | ៥៩៧.៩៩៣ | ៦.៨៦៤ | ២៧.៧៩៩ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១៩ | ៧៣១ | ២.៩៥១ | - | - |
| ប្រាក់កម្ចី | ១៣ | ៧០៨.៣២១ | ២.៨៥៩.៤៩២ | - | - |
| បុរេប្រទានពីភាគទុនិក | ១៤ | ៣០០.០០០ | ១.២១១.១០០ | - | - |
| **សរុបបំណុល** | | **១.១៥៧.១៨០** | **៤.៦៧១.៥៣៦** | **៦.៨៦៤** | **២៧.៧៩៩** |
| **មូលធន** | | | | | |
| ដើមទុន | ១៥ | ៧.០០០.០០០ | ២៨.២៥៩.០០០ | ១.០០០.០០០ | ៤.០៥០.០០០ |
| ប្រាក់ខាតបង្គរ | | (៥៩៨.៣៥៧) | (២.៤១៥.៥៦៧) | (៨១.៤៧៥) | (៣២៩.៩៧៣) |
| **សរុបមូលធន** | | **៦.៤០១.៦៤៣** | **២៥.៨៤៣.៤៣៣** | **៩១៨.៥២៥** | **៣.៧២០.០២៧** |
| **សរុបបំណុល និងមូលធន** | | **៧.៥៥៨.៨២៣** | **៣០.៥១៤.៩៦៩** | **៩២៥.៣៨៩** | **៣.៧៤៧.៨២៦** |

*កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍សវនកម្មឯករាជ្យ (ត)

## របាយការណ៍លទ្ធផល

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សំគាល់ | ការិយបរិច្ឆេទបញ្ចប់ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់៤) (មិនរងសវនកម្ម) | ការិយបរិច្ឆេទចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដុល្លារអាមេរិក (មិនរងសវនកម្ម) | ពាន់រៀល (កំណត់សំគាល់៤) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១៦ | ៣៦៩.១៧៣ | ១.៤៩០.៣៥១ | - | - |
| ចំណាយការប្រាក់ | | (១២.៣៨៧) | (៥០.០០៦) | - | - |
| **ចំណូលពីការប្រាក់សុទ្ធ** | | **៣៥៦.៧៨៦** | **១.៤៤០.៣៤៥** | **-** | **-** |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ១៧ | ១០.៦៤៤ | ៤២.៩៧០ | - | - |
| ចំណាយទូទៅ និងរដ្ឋបាល | ១៨ | (៨៨០.៥១៣) | (៣.៥៥៤.៦៣១) | (៨១.៤៧៥) | (៣២៩.៩៧៣) |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | ៨ | - | - | - | - |
| **ប្រាក់ខាតមុនដកពន្ធ** | | **(៥១៣.០៨៣)** | **(២.០៧១.៣១៦)** | **(៨១.៤៧៥)** | **(៣២៩.៩៧៣)** |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៩ | (៣.៧៩៩) | (១៥.៣៣៧) | - | - |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **(៥១៦.៨៨២)** | **(២.០៨៦.៦៥៣)** | **(៨១.៤៧៥)** | **(៣២៩.៩៧៣)** |

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | ដើមទុន ដុល្លារអាមេរិក | ប្រាក់ខាតបង្គរ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| ការបង្កើតដើមទុន (មិនរងសវនកម្ម) | ១.០០០.០០០ | - | ១.០០០.០០០ |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ (មិនរងសវនកម្ម) | - | (៨១.៤៧៥) | (៨១.៤៧៥) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ (មិនរងសវនកម្ម)** | **១.០០០.០០០** | **(៨១.៤៧៥)** | **៩១៨.៥២៥** |
| **(សមមូលពាន់រៀល-កំណត់សំគាល់៤) (មិនរងសវនកម្ម)** | **៤.០៥០.០០០** | **(៣២៩.៩៧៣)** | **៣.៧២០.០២៧** |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | ១.០០០.០០០ | (៨១.៤៧៥) | ៩១៨.៥២៥ |
| ការបង្កើនដើមទុន | ៦.០០០.០០០ | - | ៦.០០០.០០០ |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | (៥១៦.៨៨២) | (៥១៦.៨៨២) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៦** | **៧.០០០.០០០** | **(៥៩៨.៣៥៧)** | **៦.៤០១.៦៤៣** |
| **(សមមូលពាន់រៀល-កំណត់សំគាល់៤)** | **២៨.២៥៩.000** | **(២.៤១៥.៥៦៧)** | **២៥.៨៤៣.៤៣៣** |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លំហូរទឹកប្រាក់

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦*

| | កំណត់សំគាល់ | ការិយបរិច្ឆេទបញ្ចប់ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ការិយបរិច្ឆេទបញ្ចប់ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ពាន់រៀល (កំណត់សំគាល់ ៤) | ការិយបរិច្ឆេទចាប់ពី ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ (កាលបរិច្ឆេទបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដុល្លារអាមេរិក (មិនរងសវនកម្ម) | ការិយបរិច្ឆេទចាប់ពី ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ (កាលបរិច្ឆេទបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពាន់រៀល (កំណត់សំគាល់៤) (មិនរងសវនកម្ម) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ** | ២០ | (៦.៦៥០.០៦១) | (២៦.៨៤៦.២៩៦) | (១៦៤.៦១១) | (៦៦៦.៦៧៤) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ១០ | (៣៩០.៧៣៧) | (១.៥៧៧.៤០៥) | (១៩៧.៩៣៣) | (៨០១.៦២៩) |
| ការទិញទ្រព្យសកម្មអរូបី | ១១ | (២៨.០៣៧) | (១១៣.១៨៥) | (៣៦៣) | (១.៤៧០) |
| ការទិញទ្រព្យសកម្មអរូបី | | (៣០០.០០០) | (១.២១១.១០០) | (៥០.០០០) | (២០២.៥០០) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (៧១៨.៧៧៤) | (២.៩០១.៦៩០) | (២៤៨.២៩៦) | (១.០០៥.៥៩៩) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| បុរេប្រទានពីភាគទុនិក | ១៤ | ៣០០.០០០ | ១.២១១.១០០ | - | - |
| សាច់ប្រាក់ទទួលបានពីដើមទុនថ្មី | ១៥ | ៦.០០០.០០០ | ២៤.២២២.០០០ | ១.០០០.០០០ | ៤.០៥០.០០០ |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ១៣ | ៧០៨.៣២១ | ២.៨៥៩.៤៩២ | - | - |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | ៧.០០៨.៣២១ | ២៨.២៩២.៥៩២ | ១.០០០.០០០ | ៤.០៥០.០០០ |
| **ការ(ថយចុះ)/កើនឡើងនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៣៦០.៥១៤) | (១.៤៥៥.៣៩៤) | ៥៨៧.០៩៣ | ២.៣៧៧.៧២៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ | | ៥៨៧.០៩៣ | ២.៣៧០.០៩៤ | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | ២១ | ២២៦.៥៧៩ | ៩១៤.៧០០ | ៥៨៧.០៩៣ | ២.៣៧៧.៧២៧ |

*កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# ទីតាំងបណ្តាញប្រតិបត្តិការ




## ១ សាខាការិយាល័យកណ្តាល

អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស
សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
(៨៥៥) ២៣ ២២៤ ៣៣៣ / ២៣ ២២៨ ៣៣៣

## ២ សាខាខណ្ឌទួលគោក

#២៥ ផ្លូវលេខ៥៩៨ ភូមិ១ សង្កាត់បឹងកក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ
(៨៥៥) ៧០ ៣១៧ ៣៣៣




## ៣ សាខាខណ្ឌពោធិ៍សែនជ័យ

#៧៨ក, ផ្លូវជាតិលេខ៤ ភូមិព្រៃស្វាយ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

(៨៥៥) ៧០ ៣១៦ ៣៣៣

## ៤ សាខាក្រុងច្បារមន

#៤ ផ្លូវជាតិលេខ៤ ភូមិសំបូរ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

(៨៥៥) ៧០ ៣១៤ ៣៣៣

# ដៃគូសហប្រតិបត្តិការ


THE JOE COFFEE

**070 312 333**

អាសយដ្ឋាន៖ អគារលេខ ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ២២៤ ៣៣៣ / ២៣ ២២៨ ៣៣៣ ទូរសារ: (៨៥៥) ២៣ ២២២ ១៣១
អ៊ីម៉ែល: info@futabamfi.com.kh គេហទំព័រ: www.futabamfi.com.kh ហ្វេសបុក: Futaba Microfinance Plc.